

នគរវត្ត

# ស្រូវក្នុងប្រពៃណីខ្មែរ

ភិន សំណាង

## ពិធីផ្សេងៗនៅពេលដាំដុះ

ជាធម្មតានៅស្រុកខ្មែរ ភ្លៀងចាប់ផ្តើមធ្លាក់នៅដើមខែពិសាខ (ពេលខែឧសភា) អ្នកស្រុកតែងផ្តើមភ្ជួរដាស់ដីស្រែរៀងៗខ្លួនៗ អ្នកស្រុកមានជំនឿថា ដើម្បីបានភោគផលល្អ គឺគេចាំស្តាប់ផ្គរលាន់ដំបូងនៅដើមខែពិសាខពេលឮផ្គរនៅទិសខាងណាមុន គេត្រូវភ្ជួរស្រែមួយឆ្វេត បើកមុខបែរទៅទិសផ្គរលាន់នោះ ហើយភ្ជួរដាស់ដីទុកចោលសិនៗ លុះដល់ពេលមានភ្លៀងធ្លាក់ច្រើនល្មម ទើបគេចាប់ផ្តើមភ្ជួររាស់ធ្វើស្រែជាធម្មតាៗ

តាមទម្លាប់មក ការធ្វើស្រែគឺសំខាន់លើ «ពូជ» ជាគ្រាប់ស្រូវដែលគេជ្រើសរើសសម្រាប់យកទៅសាបព្រោះ ដុះស្ទូងរហូតដល់បានជាផលមកវិញៗ ការសម្រិតសម្រាំងពូជ មានទម្លាប់ខុសៗគ្នាពីគ្រួសារមួយទៅគ្រួសារមួយ ពីតំបន់មួយទៅតំបន់មួយៗ អ្នកខ្លះជ្រើសរើសពូជតាំងពីពេលច្រូត គឺយកកណ្តាប់ស្រូវណាមានផ្លែពេញក្ដួរល្អ ពុំសូវមានគ្រាប់ស្កៀតទៅបែនហើយទុកដាក់ដោយឡែកពីស្រូវដទៃទៀតៗ រីឯអ្នកខ្លះទៀតពុំមានសម្រាំងគ្រាប់ពូជជាពិសេសដូច្នេះទេ គឺគេយកស្រូវពីក្នុងជង្រុកតែម្តងក៏មានខ្លះដែរៗ អ្នកខ្លះជឿថា ពេលយកស្រូវពូជចេញពីជង្រុក គេត្រូវជ្រើសរើសថ្ងៃណាដែលគេគិតថាល្អ ហើយរបៀបដែលគេយកស្រូវចេញពីជង្រុក គឺដំបូងត្រូវកើបដោយដៃផ្ទាល់ បីកម្ប៉ង់ដាក់ក្នុងកញ្ឆេជាមុន ទើបគេកើបស្រូវតាមទម្លាប់ធម្មតា (នេះបើតាមអ្នកស្រុកប្រាសាទសម្បូណ៌ ខេត្តកំពង់ធំ)ៗ ក្រោយពីយកពូជស្រូវទៅត្រាំ និងសាបព្រោះរួចមក គ្រាប់ស្រូវទាំងនោះដុះលូតលាស់ក្លាយទៅជាសំណាប បន្ទាប់អំពីនោះមកទៀត គេត្រូវដកមកក្រោទុកមួយយប់ ឬពីរយប់សិនៗ កាលពីមុន តាមជំនឿរបស់អ្នកស្រុកខ្លះនៅខេត្តស្វាយរៀង ថាមុននឹងយកសំណាបទៅស្ទូង គេត្រូវរៀបចំពិធីមួយ គឺយកសំណាបបីកណ្តាប់មករុំនឹងសំពត់ហូល ទុកឱ្យនៅសល់ផ្នែកខាងចុងបន្តិច រួចដាក់ក្នុងល្អីមួយៗគេយកមាន់ដែលមានសម្បុរខ្មៅទៅស្ងោរទាំងមូល រួចរៀបចំបាយសម្ល នំចំណី ត្រីសាច់ដាក់ជាគ្រឿងតង្វាយៗ រួចមកគេអញ្ជើញចាស់ៗ ដែលនៅជិតខាងផ្ទះមកចូលរួមសែនព្រេន មានអុជទានធូបធ្វើពិធីបួងសួងសូមឱ្យស្រូវនោះបានផលល្អៗ ក្នុងនោះឃើញមានពាក្យអ្នកខ្លះសូត្រថា៖

> ថ្ងៃនេះថ្ងៃជា ពេលាល្អ ភូមិករព្រះធរណី រៀបចាប់ដើមពូជជាដំបូងក្នុងឆ្នាំនេះសូមឱ្យដាក់ចុះដុះឡើង ល្អដូចស្មៅ ខ្មៅដូចមរ បានគ្រាប់ទាំងថាំងៗ កុំឱ្យស្កុកស្គី។

គេសូត្របែបនេះចំនួនបីដង រួចទើបយកប្រេងដូងលាយនឹងធ្យូងធ្នាំង មកលាបនៅចុងកណ្តាប់ៗ ធ្វើកិច្ចយ៉ាងដូច្នោះហើយ ទើបគេយកកណ្តាប់នោះទៅស្ទូងនៅក្នុងស្រែជាដំបូងគេ។

សូមបញ្ជាក់ថា គេយកធ្យូងទៅលាបលើសំណាបនោះ ព្រោះចង់ឱ្យស្រូវដុះលូតលាស់ល្អ មើលទៅស្លឹកឡើងខ្មៅដូចធ្យូង គឺគេយល់ថា បើពិនិត្យទៅលើស្រែណាដែលដុះលូតលាស់ល្អ ស្រូវនោះមើលទៅហាក់ដូចជាពណ៌ខ្មៅៗ មួយទៀត អ្នកស្រុកខ្លះមានទម្លាប់ស្លៀកពាក់ខោអាវពណ៌ខ្មៅទៅធ្វើស្រែ គឺអ្នកស្រុកខ្លះពន្យល់ថា គេមានគោលបំណងឱ្យស្រូវល្អ មានស្លឹកពណ៌ខ្មៅដូចខោអាវអញ្ចឹងដែរ ដើម្បីបានផលច្រើន (ជា ណារិន, ២០០៣, ២០៥)។

បើតាមទំនៀមទម្លាប់អ្នកស្រុកវាលវែង នៅខេត្តកំពង់ធំ ដែលជាជនជាតិកួយ គឺក្រោយពីរួចរាល់កិច្ចការដកស្ទូងប្រមាណជាមួយខែ ឬពីរខែ គេមានកិច្ចមួយនៅនឹងស្រែ គឺដើម្បី «ឱ្យបាយស្រូវ»។ គេកំណត់ធ្វើនៅថ្ងៃមួយកើត ខែអស្សុជ ក្រោយពីត្រលប់មកពីវត្ត ក្នុងពិធីបុណ្យភ្ជុំបិណ្ឌវិញ គឺគេតែងរៀបចំបាយសម្ល នំចំណី បារីម្លូស្លា ព្រមទាំងមានផ្លែឈើផង យកទៅដាក់នៅនឹងមុមស្រែ ដើម្បីសែនព្រេនឱ្យនាងព្រះពៃ (ស្រូវ) ដែលកំពុងផើមៗ នៅពេលសែននោះគេមានទាំងសូត្រពាក្យសម្បូងសង្រួងផង ដូចមានពាក្យថា៖

> សូមអញ្ជើញនាងព្រះពៃ មកពីរូងពីរាម ពីពាមទន្លេ ពីកោះអំពេរ ពីថ្មអណ្តែត
> សូមអញ្ជើញមកសេពសោយក្រយា ហើយសូមឱ្យផលស្រូវឆ្នាំនេះមូលដូចដុំ
> ជុំដូចកង់។ល។

នៅតំបន់ខ្លះទៀត ឃើញមានគេប្រើប្រមដោតនៅក្នុងស្រែៗ ប្រមនោះធ្វើពីឫស្សីដែលគេច្រៀកនៅចុងម្ខាង និងត្បាញឱ្យមានរាងដូចអង្រុត ហើយដាក់ផ្កាឡើងលើៗ នៅក្នុងប្រមគេដាក់នំចំណី ផ្លែឈើ ឬអ្វីផ្សេងៗជាគ្រឿងសែនឱ្យម្រេញគង្វាល ជួយមើលថែរក្សាស្រែស្រូវរបស់គេនោះកុំឱ្យមានសត្វនានាមកបំផ្លាញ ហើយឱ្យស្រូវបានផលល្អផង (រូបលេខ១០)។ ភាគច្រើនគេដាក់ប្រមនៅក្នុងស្រែណាដែលស្ថិតនៅមុខទឹកហូរ ឬស្រែណាមានសត្វ

ក្អាម កណ្ដូប កណ្ដុរ សត្វល្អិត ឬអ្វីផ្សេងៗទៀតឧស្សាហ៍មកបំផ្លាញស្រូវញឹកញាប់ជាងគេៗ

ចាស់នៅតាមជនបទខ្លះតែងប្រាប់ក្មេងៗកុំឱ្យលេងហ៊ឹង ឬបង្ហោះខ្លែងមុនពេលស្រូវទុំ ព្រោះគេមានជំនឿថា នឹងនាំឱ្យរាំងភ្លៀង និងស្រូវស្កកជាដើមៗ នៅពេលស្រូវទុំ មានអ្នករស់នៅតាមតំបន់ខ្លះ ដូចជានៅស្រុកសូទ្រនិគមន៍ ខេត្តសៀមរាបជាដើម តែងធ្វើពិធីហៅព្រលឹងស្រូវចូលជង្រុកៗ ដំបូងគេទៅច្រូតស្រូវចំនួនបីកណ្ដាប់យកទៅទុកក្នុងកញ្ជើមួយ ហើយរៀបស្លាធម៌មួយគូរ និងកន្ទោងពីរដាក់បាយសម្ល នំចំណី រួចនិយាយបួងសួងសូមអញ្ជើញព្រលឹងនាងព្រះពៃស្រពណ៍ (ស្រូវ)ទាំង១៩ឱ្យចូលក្នុងជង្រុកៗ ក្រោយពីធ្វើពិធីនេះចប់ហើយ គេយកស្រូវបីកណ្ដាប់នោះទៅបោកដើម្បីយកគ្រាប់ស្រូវទៅក្រាលបាតជង្រុកៗ បន្ទាប់ទៅទើបគេច្រូតកាត់ បោកបែន យកស្រូវមកដាក់ជង្រុកនោះៗ ជំនឿក្នុងការធ្វើស្រែនេះពុំមែនមានតែខ្មែរទេ សូម្បីតែជនជាតិភាគតិចផ្សេងៗខ្លះនៅស្រុកខ្មែរ ក៏មានប្រពៃណី និងទំនៀមទម្លាប់រៀងៗខ្លួនដែរៗ ឧទាហរណ៍ជនជាតិគ្រឹង រស់នៅក្នុងខេត្តរតនគិរី ដំបូងគេគឺក្នុងរវាងខែមាឃ-ផល្គុន(កុម្ភៈ-មីនា) គេចាប់ផ្ដើមកាប់ព្រៃទំហំពីរទៅបីម៉ែត្រ ហើយដេកចាំមើលនៅទីនោះដើម្បីឱ្យអារក្ស ដែលជាអ្នករក្សាព្រៃពន្យល់សប្តិៗ បើគេយល់សប្ដិឃើញល្អត្រូវចាប់ផ្ដើមសែនព្រេន ដោយមានស្រាមួយពាង ឬពីរពាង មានមាន់ខ្មៅមួយ និងដាក់ដាំចេកទីនោះផង (បើដើមចេកនោះល្អមានន័យថា គេធ្វើចម្ការនៅឆ្នាំនេះនឹងបានផលល្អដែរ)ៗ គេសែនព្រេនដោយនាំគ្នាទទួលទានស្រា ព្រមទាំងមាន់នោះរួចរាល់ហើយ ស្អែកឡើងទើបមកកាប់ឆ្ការដើមឈើតូចៗឯដើមឈើណាធំៗ គេទុកចោលសិន បន្ទាប់មកទៀតគេសែនលើកទី២ ដោយធ្វើដូចលើកមុនដែរ បានគេរានព្រៃនោះម្ដងទៀតៗ ក្រោយពីកាប់ព្រៃរួចរាល់ហើយ គេត្រូវសែនម្ដងទៀត ទើបប្រមូលដុតឱ្យក្លាយទៅជាចម្ការៗ ដល់មានភ្លៀងធ្លាក់រវាងខែពិសាខ-ជេស្ឋ(ឧសភា-មិថុនា) ទើបគេចាប់ផ្ដើមដាំស្រូវៗ ក្នុងចន្លោះពេលដាំរហូតដល់ស្រូវដុះបានប្រវែងប្រហែលមួយចំអាម គេរៀបចំសែនម្ដងទៀត ដើម្បី

សូមឱ្យស្រូវលូតលាស់បានល្អៗ រហូតដល់ស្រូវចាប់ផ្ដើម គេសែនសូមកាប់ដើមរុនយកមកធ្វើជាឧបករណ៍សម្រាប់ប្រមូលផលស្រូវៗ ក្រោយមកទៀតដល់ពេលស្រូវទុំគេរៀបចំសែនដើម្បីចូលទៅបូតស្រូវៗ សូមបញ្ជាក់ថា ស្រូវដែលគេប្រមូលពីចម្ការ គឺទុកនៅក្នុងចម្ការនោះឯង ដល់ពេលយកស្រូវនោះមកដាក់ក្នុងជង្រុកនៅឯផ្ទះក៏គេត្រូវសែនព្រេនជាមុនដែរៗ

សេចក្ដីបរិយាយខ្លីៗមកប៉ុណ្ណេះក៏អាចយល់ហើយថា ស្រូវជាដំណាំដែលឆ្លងកាត់ការដាំដុះច្រើនដំណាក់កាល ហើយមានក្បួនខ្នាតច្បាស់លាស់ ព្រមទាំងរហូតដល់មានកិច្ចពិធីតាមជំនឿផ្សេងៗផង ទម្រាំបានផលយកមកបរិភោគៗ តម្រាធ្វើស្រែ-ចម្ការខ្លះ ពន្យល់ពីការជ្រើសរើសពេលវេលា និងកិច្ចការដែលត្រូវធ្វើខ្លះ ដូចមានឧទាហរណ៍ខាងក្រោម៖

## សិទ្ធិអារ្យ

របៀបធ្វើស្រែ បុរាណបានកែ តម្រាទុកមក
ជាច្បាប់ប្រាប់ប្រៀន ប្រដៅគួរយក តម្រាប់ត្រាប់រក
របរការស្រែ។

ព្រោះសាបស្លូងស្រូវ ផ្សំតាមរដូវ តម្រូវតាមខែ
ខះខំឱហាត សង្វាតមើលថែ ទើបបានផ្កាផ្លែ
ពីស្រែស្រូវនោះ។